ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation Religion King**

**កំពង់ផែស្វយ័តភ្នំពេញ**
**Phnom Penh Autonomous Port**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងពង្រីកសមត្ថភាពចំណតផែកុងតឺន័រថ្មី(LM១៧) ជំហានទី២

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) បានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅលើផ្សារមូលបត្រកម្ពុជា (CSX) នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ កន្លងទៅ។ ក្រៅពីគោលបំណងពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាពនៃការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម និងអភិបាលកិច្ចល្អរបស់សហគ្រាស គោលបំណងសំខាន់ក្នុងការបោះលក់មូលបត្រនោះ គឺដើម្បីស្វែងរកប្រភពមូលធនពីវិនិយោគិនឯកជនយកមកអភិវឌ្ឍគម្រោងវិនិយោគរយៈពេលខ្លីរបស់ ក.ស.ភ ដែលបានគ្រោងឡើងក្នុងរយៈពេលបីឆ្នាំខាងមុខ គឺចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ក្នុងគោលដៅពង្រឹងនិងពង្រីកសមត្ថភាពរបស់ ក.ស.ភ. ទៅថ្ងៃមុខ។

គម្រោងវិនិយោគរយៈពេលខ្លីនេះមានពីរ រួមមាន៖ ១). គម្រោងពង្រីកសមត្ថភាពចំណតផែកុងតឺន័រថ្មី (LM១៧) ជំហានទី២ និង ២). គម្រោងបំពាក់ខ្សែកុងរ៉ូយ័រនៅតាមទីតាំងជាយុទ្ធសាស្ត្រមួយចំនួន សម្រាប់បម្រើឱ្យការលើកដាក់ផ្ទេរផ្ទុកទំនិញរាយ។ បច្ចុប្បន្ននេះ ក.ស.ភ. បាននិងកំពុងអនុវត្តគម្រោងទី០១ គឺការពង្រីកសមត្ថភាពចំណតផែកុងតឺន័រថ្មី (LM១៧) ជាជំហានទី២ ដើម្បីបង្កើនសមត្ថភាពរបស់ចំណតផែកុងតឺន័រថ្មី (LM១៧) ឱ្យទទួលបានសមត្ថភាពទ្វេដងលើសសមត្ថភាពដែលមានបច្ចុប្បន្ននេះ។ មានន័យថា សព្វថ្ងៃនេះចំណតផែកុងតឺន័រថ្មី (LM១៧) នៅជំហានទី១ ដែលបានដាក់ឱ្យដំណើរការប្រតិបត្តិការកាលពីឆ្នាំ២០១៣ កន្លងមកនេះ មានទីលានស្តុកកុងតឺន័រចំនួន ៨កន្លែង ដែលមានសមត្ថភាពទទួលកុងតឺន័របានចំនួន ១៥០.០០០TEUs ក្នុងមួយឆ្នាំ នឹងត្រូវបង្កើនសមត្ថភាពរបស់ខ្លួនឱ្យបានរហូតដល់ចំនួន ៣០០.០០០TEUs ក្នុងមួយឆ្នាំ នៅបំណាច់ឆ្នាំ២០១៨។

ការពង្រីកសមត្ថភាពចំណតផែកុងតឺន័រថ្មី(LM១៧) ជំហានទី២នេះ គឺដើម្បីឆ្លើយតបនឹងកំណើនបរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ ដែលមានកំណើនជារៀងរាល់ឆ្នាំ។ ជាក់ស្តែង សម្រាប់ឆ្នាំ២០១៥ កន្លងមកនេះ ចំណតផែកុងតឺន័រថ្មី(LM១៧) ទទួលបានបរិមាណកុងតឺន័រចំនួន ១៤៤.៨១៣TEUs (មានកំណើន ៨.៣% ប្រៀបធៀបនឹងឆ្នាំ២០១៤ ដែលមានចំនួន ១៣៣.៦៦៦TEUs) ដែលបរិមាណនេះ ឃើញថា ស្ទើរតែដល់កម្រិតសមត្ថភាពសម្រាប់ជំហានទី១ នៃចំណតផែកុងតឺន័រ(LM១៧) ដូចដែលបានលើកឡើងខាងលើ។

ចំពោះការងារអនុវត្តជាក់ស្តែង សម្រាប់គម្រោងពង្រីកសមត្ថភាពចំណតផែកុងតឺន័រថ្មី (LM១៧) ជំហានទី២នេះ ក.ស.ភ. បានចាប់ផ្តើមអនុវត្តមុនការគ្រោងទុក (ឆ្នាំ២០១៦) ដោយចាប់អនុវត្តពីឆ្នាំ២០១៥ មកជាបណ្តើរៗ។ គម្រោងនេះត្រូវបានបែងចែកជាពីរដំណាក់កាលក្នុងការអនុវត្តការងារ គឺដំណាក់កាលទី១ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦

ទីចាត់ការកណ្តាល: អគារលេខ ៦៤៩ តិរ:វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh

និងដំណាក់កាលទី២ នៅឆ្នាំ២០១៦ ដល់២០១៧។ សម្រាប់ការងារចម្បងក្នុងការអនុវត្ត នៅដំណាក់កាលទី១ រួមមាន ការងារពង្រីកទីលានស្តុកកុងតឺន័រ(Container Yard) ចំនួន ០២កន្លែង(ទីលានទី៥ និងទី៦) បន្ថែមទៀត ដែលមានផ្ទៃក្រឡាសរុបទំហំ ១១.៩៦៨ម៉ែត្រការ៉េ។ ដើម្បីសម្រេចបានទីលានស្តុកកុងតឺន័រនីមួយៗបាន ទាមទារនូវការងារសាងសង់ផ្លូវរត់សម្រាប់រថស្ទូច RTG ចំនួន ០១ខ្សែ(ប្រវែង ២៧២ម៉ែត្រ) ការងារសាងសង់ផ្លូវសម្រាប់ រថយន្តកុងតឺន័រចំនួន ០១ខ្សែ(ប្រវែង ២៧២ម៉ែត្រ) និងការបំពាក់រថស្ទូច RTG ចំនួន ០១គ្រឿង។ រហូតដល់សព្វថ្ងៃ ការងារខាងលើសម្រេចបានជាង ៦០% (គិតត្រឹមថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦) រួចហើយ បើតាមការគ្រោងទុកនោះ នឹងបញ្ចប់រួចរាល់ជាស្ថាពរនៅពាក់កណ្តាលខែមីនា ឆ្នាំ២០១៦ ខាងមុខនេះ។ ដូចនេះ នៅពេលទីលានស្តុកកុងតឺន័រទាំងពីរខាងលើ ត្រូវបានសាងសង់ និងបំពាក់គ្រឿងចក្ររួចរាល់ នោះសមត្ថភាពលើកដាក់របស់ ក.ស.ភ. លើទីលានស្តុកកុងតឺន័រទាំងពីរនឹងអាចប្រតិបត្តិការទទួលកុងតឺន័របន្ថែម ៧៥.០០០TEUs ក្នុងមួយឆ្នាំ។

ចំពោះការងារអនុវត្តនៅដំណាក់កាលទី២ នៃគម្រោងពង្រីកសមត្ថភាពចំណតផែកុងតឺន័រថ្មី (LM១៧) ជំហានទី២ យើងនឹងអនុវត្តការងារដូចគ្នាដែរ គឺ ការងារពង្រីកទីលានស្តុកកុងតឺន័រចំនួន ០២កន្លែង បន្ថែមទៀត (ទីលានទី៧ និងទី៨) ដែលមានផ្ទៃក្រឡាសរុបទំហំ ១១.៩៦៨ម៉ែត្រការ៉េ។ ដូចគ្នានឹងដំណាក់កាលទី១ ផងដែរ ទីលានស្តុកកុងតឺន័រនីមួយៗត្រូវមាន ផ្លូវរត់សម្រាប់រថស្ទូច RTG ចំនួន ០១ខ្សែ(ប្រវែង ២៧២ម៉ែត្រ) ផ្លូវសម្រាប់ រថយន្តកុងតឺន័រចំនួន ០១ខ្សែ(ប្រវែង ២៧២ម៉ែត្រ) និងបំពាក់គ្រឿងចក្រ RTG ចំនួន ០១គ្រឿង ហើយការងារទាំងអស់នេះ នឹងត្រូវអនុវត្តឱ្យសម្រេចបាននៅបំណាច់ឆ្នាំ២០១៧។ នៅពេលបញ្ចប់ការងារដំណាក់កាលទី២ នៃជំហានទី២នេះ សមត្ថភាពលើកដាក់របស់ទីលានទាំងពីរ នឹងទទួលបានបន្ថែម ៧៥.០០០TEUs ក្នុងមួយឆ្នាំ ។

ដោយឡែក ចំពោះការបំពាក់គ្រឿងចក្រ RTG ចំនួន០៤គ្រឿង ទៅលើទីលានស្តុកកុងតឺន័រទាំង ០៤កន្លែងនេះ ក.ស.ភ. បាននិងកំពុងចរចាជាមួយក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងចក្រ RTG នេះ អំពីលក្ខណៈបច្ចេកទេស តម្លៃ និងបែបបទនៃការដឹកជញ្ជូន ព្រមទាំងការតម្លើង និងធ្វើតេស្តគ្រឿងចក្រនេះ ហើយតាមការគ្រោងទុក គ្រឿងចក្រទាំង០៤គ្រឿងនោះ នឹងមកដល់ចំណតផែកុងតឺន័រថ្មី(LM១៧) នៅបំណាច់ឆ្នាំ២០១៧។

ដូចនេះ បន្ទាប់ពីការសាងសង់ទីលានកុងតឺន័រ ទាំង០៤កន្លែង បន្ថែមលើទីលានដែលមានស្រាប់ បានបញ្ចប់សព្វគ្រប់ និងគ្រឿងចក្រត្រូវបានតំឡើងរួចរាល់ ក.ស.ភ. រំពឹងទុកថា សមត្ថភាពចំណតផែកុងតឺន័រថ្មី(LM១៧) នឹងអាចទទួលបានសមត្ថភាពលើកដាក់សរុបប្រចាំឆ្នាំបានដល់ ៣០០.០០០TEUs ដូចដែលបានគ្រោងទុក ហើយការងារទាំងអស់ខាងលើ នឹងអាចបញ្ចប់មុនបំណាច់ឆ្នាំ២០១៨ ដើម្បីបម្រើសេវាកម្មដល់អតិថិជន ទៅតាមតម្រូវការ និងកំណើនកុងតឺន័រ ដែលមានការកើនឡើងជាលំដាប់។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦

**កំពង់ផែស្វយ័តភ្នំពេញ**

ទីចាត់ការកណ្តាលៈ អគារលេខ ៦៤៩  តិរៈវិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥)២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Prah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh